# ស្ថានទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

## សុន្ទរកថារបស់ឯកឧត្តម យូជី គូម៉ាម៉ារូ
## ឯកអគ្គរាជទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា
## ក្នុងពិធីដាក់អោយប្រើប្រាស់ជាបណ្តោះអាសន្នបណ្តាញលូមេដែលត្រូវបានសាងសង់
## ក្រោមគំរោងការពារទឹកជំនន់ និងកែលំអប្រព័ន្ធប្រឡាយ-លូ នៅរាជធានីភ្នំពេញ
## (ជំហានទី ៣)

ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៣

សូមគោរព **ឯកឧត្តម ប៉ា សុជាតិវង្ស** អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ

សូមគោរពឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយស លោកស្រី និង អស់លោកទាំងអស់

ខ្ញុំមានសេចក្តីសោមស្សរីករាយយ៉ាងក្រៃលែងដែលបានមកចូលរួមនៅថ្ងៃនេះ ពិធីដាក់អោយប្រើប្រាស់ជាបណ្តោះអាសន្នបណ្តាញលូមេដែលត្រូវបានសាងសង់ក្រោមគំរោងការពារទឹកជំនន់ និងកែលំអប្រព័ន្ធប្រឡាយ-លូនៅរាជធានីភ្នំពេញ (ជំហានទី ៣) ។ ជាបឋម ខ្ញុំសូមសម្តែងនូវកត្តញ្ញូតាធមិដោយស្មោះសរចំពោះ **ឯកឧត្តម ប៉ា សុជាតិវង្ស** អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ និង មន្ត្រី-រាជការនៃសាលារាជធានីភ្នំពេញទាំងអស់ចំពោះការរៀបចំអោយមានពិធីដ៏ឧឡារិកនៅថ្ងៃនេះ ។

ខ្ញុំក៏មានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងផងដែរដែលពិធីសម្រាប់គម្រោងដ៏សំខាន់នេះ ត្រូវបានប្រារព្ធឡើងនៅក្នុងបរិបទដ៏ពិសេសនៃឆ្នាំ ២០១៣ នេះដែលជាឆ្នាំខួបអនុស្សាវរីយ៍លើកទី ៦០ នៃទំនាក់ទំនងមិត្តភាពជប៉ុន-កម្ពុជា ។

រាជធានីភ្នំពេញ ត្រូវប្រឈមជារៀងរាល់ឆ្នាំទៅនឹងហានិភ័យនៃទឹកជំនន់រដូវវស្សា និង ទទួលរងនូវការលំបាកជាប្រចាំដោយការជន់លិច និង ការកកស្ទះនៃប្រព័ន្ធបណ្តាញលូបង្ហូរទឹកក្រខ្វក់ ។ ស្ថានភាពនេះបាននាំមកនូវផលប៉ះពាល់ជាអវិជ្ជមានដល់ការធ្វើដំណើរ ការដឹកជញ្ជូន បរិស្ថានអនាម័យ និងសកម្មភាពសេដ្ឋកិច្ចដែលធ្វើអោយរាំងស្ទះដល់ដំណើរការប្រព្រឹត្តិទៅដោយរលូនរបស់រាជធានី ។

រដ្ឋាភិបាលជប៉ុន ដោយមានការយល់ដឹងយ៉ាងច្បាស់អំពីអត្ថប្រយោជន៍នៃការកែលំអធ្វើអោយប្រសើរឡើងនូវប្រព័ន្ធប្រឡាយ - លូបង្ហូរទឹកក្រខ្វក់ថាជាកូនសោគន្លឹះមួយដើម្បីកាត់បន្ថយភាពជន់លិចលង់នោះបានផ្តល់ហិរញ្ញប្បទានឥតសំណងចំនួនបួនពាន់ប្រាំពីររយលានយ៉េន (៤.៧០០ លានយ៉េន) ប្រាក់ជប៉ុនប្រហែលស្មើនឹង ៥៩ លានដុល្លារ៍អាមេរិក ដើម្បីអនុវត្តជំហានទី ១ និង ជំហានទី ២ នៃគំរោងនេះនៅឆ្នាំ ២០០២ និង ២០០៧ រៀងមក ។ ជាមួយនឹងជំនួយឧបត្ថម្ភនេះ ប្រព័ន្ធប្រឡាយ-លូបង្ហូរទឹកក្រខ្វក់នៅតំបន់ភាគខាងត្បូងឆៀងខាងលិច និងតំបន់ភាគខាងជើងឆៀងខាងកើតនៃរាជធានីត្រូវបានកែលំអធ្វើអោយប្រសើរឡើង ហើយភាពជន់លិចលង់ធ្ងន់ធ្ងរមិនបានកើតមាននៅក្នុងតំបន់ទាំងនោះឡើយដូចជានៅតំបន់ផ្សារធំថ្មី វត្តភ្នំ សារមន្ទីរជាតិ និងតាមបណ្តោយមហាវិថីម៉ៅសេទុងជាដើម ។

ជំហានទី ៣ នៃគំរោងនេះមានទឹកប្រាក់សរុបចំនួនបីពាន់ប្រាំពីររយលានយ៉េន (៣.៧០០ លានយ៉េន) ប្រាក់ជប៉ុនប្រហែលស្មើនឹង ៤៦ លានដុល្លារ៍អាមេរិក គ្របដណ្តប់តំបន់ចំនួន ៨ នៅភាគខាងត្បូងឆៀងខាងកើតនៃរាជធានី ។ ក្នុងចំណោមតំបន់ទាំងនេះ ការងារសាងសង់មួយចំនួននៅតំបន់ទួលស្លែង បឹងកេងកង និងទួលទំពូង ត្រូវបានបញ្ចប់ ។

## ឯកឧត្តម លោកជំទាវ លោកស្រី និងអស់លោកទាំងអស់

ខ្ញុំដឹងថា ការងារសាងសង់បានបង្ករអោយមានការរំខានជាច្រើនដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន ជាពិសេសលោក-អ្នកដែលរស់នៅជុំវិញតំបន់ទីតាំងគំរោង ។ ខ្ញុំសូមឆ្លៀតឱកាសនេះដើម្បីស្នើសុំការយោគយល់ និងកិច្ចសហប្រតិបត្តិការពីសំណាក់បងប្អូនប្រជាពលរដ្ឋនៅទីក្រុងភ្នំពេញ ។ ជាការពិតលោក-អ្នកប្រហែលជាអាចមានការធុញទ្រាន់ខ្លាំងក្នុងរយៈពេលនៃការសាងសង់នេះ ប៉ុន្តែភាពជន់លិចលង់នឹងត្រូវបានកាត់បន្ថយយ៉ាងច្រើននៅពេលដែលគំរោងនេះត្រូវបានបញ្ចប់ ។

ដើម្បីអោយប្រព័ន្ធប្រឡាយ-លូបង្ហូរទឹកក្រខ្វក់នេះរក្សាបាននូវមុខងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាពខ្ពស់នោះ ការយល់ដឹងពីសំណាក់លោក-អ្នកជាប្រជាពលរដ្ឋគឺមានសារៈសំខាន់ខ្លាំងណាស់ ។ ដោយហេតុនេះ ខ្ញុំសំណូមពរដល់ប្រជាពលរដ្ឋនៅទីក្រុងភ្នំពេញ សូមមេត្តាកុំដាក់សំរាមចោលនៅលើផ្លូវថ្នល់ និងនៅតាមផ្លូវទឹកដែលហូរ ។ ទាក់ទងនឹងបញ្ហានេះដែរ ខ្ញុំក៏សូមស្វាគមន៍ និងគាំទ្រយ៉ាងខ្លាំងក្លាដល់គំនិតផ្តួចផ្តើមរបស់ឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានី

ភ្នំពេញនៅក្នុងការផ្តួចផ្តើមអោយមានសកម្មភាពចុះស្តារប្រមូលកាកសំរាមលាងសំអាតអណ្តូងលូនានា និងប្រពន្ធ័ប្រឡាយ-លូដែលមានស្រាប់ ។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាតាមរយៈគំរោងនេះរាជធានីភ្នំពេញនឹងរីករាយជាមួយនឹងការអភិវឌ្ឍន៍ និង វិបុលភាពជាបន្តទៅទៀតតាមរយៈការដែលអាចរំដោះខ្លួនចេញពីការខូចខាតយ៉ាងធ្ងន់ធ្ងរដោយទឹកជំនន់ ។ គំរោងកិច្ចសហប្រតិបត្តិការនេះក៏នឹងជួយលើកកំពស់មុខមាត់រាជធានីភ្នំពេញ ដែលនឹងនាំមកនូវផលជាវិជ្ជមានសំរាប់ការវិនិយោគទុនពីបរទេស និង ពីវិស័យទេសចរណ៍ ។

សូមអរគុណ ។